# ការផាកពិន័យរហូតដល់១០០,០០០វ៉ុន
# សម្រាប់ការមិនពាក់ម៉ាសនៅទីកន្លែងសាធារណៈជាច្រើនចាប់ពីថ្ងៃទី១៣ខែវិច្ឆិកា

□គោលដៅ ពិន័យ

▲ករណីមិនពាក់ម៉ាស

▲ករណីពាក់ម៉ាស, តែមិនគ្របដណ្តប់មាត់និងច្រមុះទាំងស្រុង

▲ការពាក់ម៉ាស ប្រភេទសំណាញ់ឬ ប្រភេទរបាំងសន្ទះបិទបើកឬ គ្របមុខដោយក្រម៉ាឬសម្លៀកបំពាក់ ផ្សេងៗទៀត

☞ប្រភេទម៉ាសដែលទទួលស្គាល់

: KF94, KF80, ម៉ាសប្រឆាំងនឹងដំណក់ទឹកនិងម៉ាសប្រើពេលវះកាត់, ម៉ាសក្រណាត់, ម៉ាសប្រើម្តងចោល។ល។

**កាតព្វកិច្ចពាក់ម៉ាស់គឺ អនុវត្តខុសគ្នាទៅតាមទីកន្លែងនីមួយៗនិងទីតាំងដែលមានហានិភ័យនៃការឆ្លងជំងឺ ដោយយោងតាម តំណាក់កាល ការរក្សាចម្ងាយ។**

| ការបែងចែក | កន្លែងគោលដៅ |
|---|---|
| កន្លែង គ្រប់គ្រង ស្មុល (៩ប្រភេទ) | ▲កន្លែងកម្សាន្ត ៥ប្រភេទ (កន្លែងកំសាន្តដូចជា ក្លឹប-ហាងជាបន្ទប់, រង្គសាល, បារវ៉ូមេទិច(បារបាំង), ក្លឹបរាំជាគូរ, ហាងស្រាសម្រាប់បុរសនិង ស្ត្រីណាត់ជួបគ្នាលើកដំបូង<br>▲បន្ទប់ហាត់ច្រៀង ▲សាលសំដែងនៅខាងក្នុងបរិវេណ ▲មណ្ឌលផ្សព្វផ្សាយលក់ដូរដោយផ្ទាល់ ដូចជាការលក់ដូរតាមផ្ទះ<br>▲ភោជនីយដ្ឋាន· ហាងកាហ្វេ (ការបើកអាជីវកម្ម ភោជនីយដ្ឋានទូទៅ·ភោជនីយដ្ឋានដែលមានកន្លែងសម្រាក·ហាងនំប៉័ង) |
| កន្លែង គ្រប់គ្រង ទូទៅ (១៤ប្រភេទ) | ▲បន្ទប់កុំព្យូទ័រ ▲សាលប្រារព្ធអាពាហ៍ពិពាហ៍ ▲សាលប្រារព្ធពិធីបុណ្យសព ▲សាលាអប់រំឯកជន(រួមទាំងទីកន្លែងហ្វឹកហាត់) ▲វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ<br>▲កន្លែងងូតទឹក ▲សាលសំដែង ▲រោងកុន ▲សួនកំសាន្ត.កន្លែងលេងទឹក ▲បន្ទប់លេងល្បែងតាមកុំព្យូទ័រ·បន្ទប់កំសាន្ត។ល។<br>▲ក្នុងបរិវេណកន្លែងហាត់កីឡា ▲ហាងសម្អាងការ·ហាងកែសម្ផស្ស ▲ផ្សារម៉ាត·ផ្សារទំនើប ▲បន្ទប់អានសៀវភៅ·ការសិក្សានៅហាងកាហ្វេ |

○ ការរក្សាគម្លាតចម្ងាយសង្គមតំណាក់កាលទី១: ទីកន្លែង ស្មុល·គ្រប់គ្រងទូទៅ (មាន ២៣ប្រភេទ), យានជំនិះសាធារណៈ, ការប្រមូលផ្តុំ· ការធ្វើបាតុកម្ម,ស្ថាប័នវេជ្ជសាស្ត្រ·ឱសថស្ថាន, ទីកន្លែងថែទាំមនុស្សចាស់ជរានិងទីកន្លែងការពារពេលថ្ងៃ·យប់, ស្ថាប័នសាសនា, ទីកន្លែងក្នុងបរិវេណពហុកីឡាដ្ឋាន, កន្លែងធ្វើការដែលមានហានិភ័យខ្ពស់ (មជ្ឈមណ្ឌលហៅទូរស័ព្ទ,មជ្ឈមណ្ឌលដឹកជញ្ជូននិង ចែកចាយ)ការប្រជុំ និងព្រឹត្តិការណ៍ដែលមានមនុស្ស៥០០នាក់ឡើងត្រូវបានរាយការណ៍និងពិភាក្សាជាមួយរដ្ឋាភិបាលក្នុងតំបន់

○ ការរក្សាគម្លាតចម្ងាយសង្គម តំណាក់កាល១.៥: តំណាក់កាលទី១ និងរួមបញ្ចូល ទីកន្លែងក្រៅបរិវេណពហុកីឡាដ្ឋាន

○ ការរក្សាគម្លាតចម្ងាយសង្គម តំណាក់កាលទី២ : ក្នុងបរិវេណនិង ក្រៅបរិវេណ ទាំងមូល រាល់សកម្មភាពដែលមានហានិភ័យខ្ពស់

○ ការរក្សាគម្លាតចម្ងាយសង្គមតំណាក់កាល២.៥និង៣ : ក្នុងបរិវេណ និងខាងក្រៅបរិវេណទាំងមូលដែលមិនអាចរក្សាចម្ងាយលើសពី ២ម៉ែត្រ

○ អ្នកគ្រប់គ្រង (ប្រតិបត្តិករ) និងអ្នកទទួលបន្ទុកគឺ ប្រាកដណាស់ មានកាតព្វកិច្ចពាក់ម៉ាស ដូចជាអ្នកប្រើប្រាស់ផងដែរ

※ មធ្យោបាយនិងទីកន្លែងដែលរងការពិន័យអាចត្រូវបានកែសម្រួល ទៅតាមរដ្ឋាភិបាលមូលដ្ឋាននីមួយៗក្នុងការពិចារណាលើការរីករាលដាលនៃកូវីដ១៩

□គោលដៅលើកលែង

▲អ្នកដែលពិបាកពាក់ឬដោះម៉ាសដោយខ្លួនឯងដោយគ្មានជំនួយពីអ្នកដទៃដូចជាជនពិការភាពនៃការលូតលាស់ផ្នែកណាមួយ

▲អ្នកដែលវេជ្ជបណ្ឌិតបញ្ជាក់ថាការដកដង្ហើមពិបាកពេលពាក់ម៉ាស

▲អ្នកដែលមិនទាន់គ្រប់អាយុ១៤ឆ្នាំ

▲នៅពេលអ្នកលាងមុខ, បរិភោគអាហារ, អនុវត្តផ្នែកវេជ្ជសាស្ត្រ, អាងហែលទឹកនិងងូតទឹក។ល។

▲ក្នុងស្ថានភាពដែលជៀសមិនរួចត្រូវ បង្ហាញមុខតាមការសម្តែង។ល។

<ការបកប្រែនេះ គឺធ្វើឡើងនៅមជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទដានូរី ១៥៧៧-១៣៦៦។>